**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៩៣ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីរាតយកដីធ្វើកម្មសិទ្ធិនៅតាមបណ្តាខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីរាតយកដីធ្វើកម្មសិទ្ធិនៅតាមបណ្តាខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ចេង សាខុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-ឯកឧត្តម | **អ៊ុច សំអាត** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធានប្រចាំការ |
| ៣-ឯកឧត្តម | **តេង សាវង្ស** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤-ឯកឧត្តម | **ខួយ ឃុនហ៊ួរ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តម | **ស្តើង សុខុម** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-ឯកឧត្តម | **សរ សុវណ្ណា** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧-ឯកឧត្តម | **ស្រ៊ុន ដារិទ្ធិ** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨-ឯកឧត្តម | **ឡុង នរិន្ទ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៩-ឯកឧត្តម លោកជំទាវ | **អភិបាលនៃគណៈអភិបាលខេត្ត** | | សមាជិក |
| ១០-ឯកឧត្តម | **កែវ អូម៉ាលីស្ស** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ១១-ឯកឧត្តមនាយឧត្តមសេនីយ៍ | **អ៊ុយ សារិទ្ធ** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១២-ឯកឧត្តមនាយឧត្តមសេនីយ៍ | **ហ៊ី សាគុណា** | អគ្គស្នងការរងនៃនគរបាលជាតិ | សមាជិក |
| ១៣-លោកឧត្តមសេនីយ៍ឯក | **ប៉ោ វណ្ណៈ** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក។ |

**ប្រការ២.-**

គណៈកម្មាធិការជាតិនេះ មានតួនាទី និងភារកិច្ចដូចតទៅ៖

១- រៀបចំ និងអនុវត្តផែនការសកម្មភាពផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានដែលពាក់ព័ន្ធទៅនឹងដីព្រៃឈើគ្រប់ប្រភេទ។

២- ត្រួតពិនិត្យ និងស្រាវជ្រាវដល់មូលដ្ឋានដែលមានការកាប់រានដីព្រៃខុសច្បាប់ក្នុងគោលបំណងធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬទុកធ្វើអាជីវកម្មបន្ត។

៣-ចាត់វិធានការទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបឱ្យទាន់ពេលវេលានូវរាលការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើគ្រប់ប្រភេទ។

៤- ធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីជំរុញ និងគាំទ្រការងារនេះ។

៥- ធ្វើរបាយការណ៍ និងលើកអនុសាសន៍ជូនរាជរដ្ឋាភិបាលលើការអនុវត្តផែនការសកម្មភាព។

៦- បង្កើតយន្តការអនុវត្តតាមខេត្តនីមួយៗតាមការចាំបាច់នូវអនុគណៈកម្មាធិការមួយ ដែលមានឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តជាប្រធាន ដើម្បីបំពេញការងារអនុវត្តភារកិច្ចនានាដែលគណៈកម្មាធិការជាតិផ្តល់ឱ្យ។

**ប្រការ៣.-**

សមាជិកគណៈកម្មាធិការជាតិ ត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខណ្ឌសមត្ថកិច្ច ភារកិច្ចរបស់ខ្លួន និងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៤.-**

គណៈកម្មាធិការជាតិនេះ មានអគ្គលេខាធិការដ្ឋានប្រតិបត្តិជាជំនួយការដែលមានអនុប្រធានប្រចាំការនៃគណៈកម្មាធិការជាតិនេះជាប្រធាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សមាសភាពអគ្គលេខាធិការដ្ឋានប្រតិបត្តិ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៥.-**

រាល់ការចំណាយរបស់អគ្គលេខាធិការដ្ឋាន ជាបន្ទុករបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៦.-**

គណៈកម្មាធិការជាតិ មានសិទ្ធិចាត់តាំងក្រុមការងារផ្សេងទៀតតាមការចាំបាច់។

**ប្រការ៧.-**

អនុគណៈកម្មការដែលជាយន្តការអនុវត្តមានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលខេត្ត។

**ប្រការ៨.-**

សេចក្តីសម្រេចលេខ៣២ សសរ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា សេចក្តីសម្រេចលេខ០១ សសរ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥ កើត ខែបឋមាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ៩
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

<u>លេខ ១១៩ ចល.កសក</u>

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមក៖**

**- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**"ដើម្បីជូនជ្រាប"**

-ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត

"ដើម្បីជ្រាប និងមុខការ"

ថ្ងៃ ច័ន្ទ ៧ កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០១៩

**ត.ប រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

**ស្រី ឧត្តរី**